# សំអាងហេតុសន្និដ្ឋានលើបទល្មើស

**ក.** យល់ឃើញថា *ការដែលសាលាដំបូងរាជធានីភ្នំពេញនិងសាលាឧទ្ធរណ៍សំរេចប្រកាសទោសនិងផ្តន្ទាទោសលើជនត្រូវចោទ ឈ្មោះ...**វណ្ណណាត** ពីបទចាប់ឃុំឃាំងនិងបង្ខាំងដោយខុសច្បាប់ក្នុងគោលដៅជំរិតទារប្រាក់និងកាន់កាប់អាវុធដោយខុសច្បាប់ មានសំអាងហេតុនិងសេចក្តីសំរេចផ្ទុយគ្នា ពីព្រោះថាតាមចម្លើយសាក្សីឈ្មោះ **...វីសាល** ជាអ្នកទទួលភ្ញៀវនៅសណ្ឋាគារខ្សាច់មាស និង**...សារ៉ែត** ជាអ្នកទទួលភ្ញៀវនៅបឹងកាឡូអូរឈើទាល ពុំបានបញ្ជាក់អំពីហេតុនៃអំពើល្មើសទេ តែបញ្ជាក់អំពីការស្រុះស្រួលគ្នាមកជួលស្នាក់នៅតែប៉ុណ្ណោះ។*

សម្រេច....បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៤៦ចុះថ្ងៃ ទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ (សាលដីកាតុលាការកំពូលលេខ១៥៧, ឆ្នាំ ២០១៣, ទំ.៥-៦)។

**កំណត់សំគាល់៖** ការសម្រេចថាជាបទល្មើសអ្វីមួយ ត្រូវមានសំអាងផ្អែកលើភស្តុតាងរឹងមាំ។ បទចាប់ឃុំឃាំងក្នុងមាត្រា២៥៣(ខាងក្រោម) តម្រូវឲ្យមានជាតុផ្សំបង្ខិតបង្ខំ (មិនព្រមព្រៀង)។ អង្គហេតុបានបង្ហាញថា មានការស្រុះស្រួលគ្នា។ នេះនាំឲ្យតុលាការកំពូលសន្និដ្ឋានថា សំអាងហេតុនិងសេចក្តីសម្រេចផ្ទុយគ្នា ដែលត្រូវបង្វិលសំណុំរឿងទៅវិញតាមមាត្រា៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា២៥៣ បទចាប់ឃុំឃាំងនិងបង្ខាំងដោយខុសច្បាប់**

បុគ្គលដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំងបុគ្គលផ្សេងទៀតដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ឬក្រៅពីករណីដែលច្បាប់អនុញ្ញាតត្រូវផ្តន្ទាទោស ៖

១- ដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី) ឆ្នាំបើការចាប់ ការឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេល តិចជាង៤៨ (សែសិបប្រាំបី) ម៉ោង ។...

៣- ដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំបើការចាប់ ការឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេល ស្មើ ឬលើសពី ១ (មួយ) ខែ ។

សម្រាប់សាលក្រម និងសាលដីកាពាក់ព័ន្ធសូមចុះលើតំណភ្ជាប់នេះ។